# របាំទន្សោង

នៅក្នុងតំបន់ខាងត្បូងទន្លេសាប មានរបាំមួយដែលគេហៅថា របាំរាំស្នែងទន្សោង របាំស្នែងទន្សោង ឬរបាំទន្សោង។ គេឃើញរបាំនេះមាននៅក្នុងខេត្តមួយចំនួនដូចជា ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ និងខេត្តពោធិសាត់។ នៅឯទីក្រុងភ្នំពេញ សាលាមធ្យមវិចិត្រសិល្បៈ សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និងនាយកដ្ឋានទស្សនីយភាព ក៏មានសម្តែងរបាំទន្សោងនេះដែរ។

គេហៅរបាំនេះថា របាំទន្សោង ដោយសារខ្លឹមសារសំខាន់របស់របាំ ពាក់ព័ន្ធនឹងសត្វទន្សោង មានសម្លៀកបំពាក់ ស្នែងទន្សោង និងចលនាកាយវិការរាំត្រាប់តាមសត្វទន្សោង។ នៅភូមិអញ្ចាញរូង ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង មានរឿងព្រេងមួយនិទានថា៖ ថ្ងៃមួយព្រះរាជាទ្រង់ត្រាស់បញ្ជាឱ្យព្រានម្នាក់ឈ្មោះ «ព័រ» ចេញទៅបរបាញ់សត្វ។ ក្រោយពីស្វែងរកសត្វព្រៃពេញមួយយប់តែពុំបានជោគជ័យ ព្រាននោះក៏បានមកដល់វាលមួយ ហើយបានឃើញទិដ្ឋភាពដ៏ចម្លែកមួយ គឺសត្វទន្សោងញីឈ្មោលមួយគូកំពុងបែរចង់និងរេរាំជាមួយគ្នា ព្រមទាំងមានសត្វកន្ធង់ហើរក្រឡឹងជុំវិញសត្វទន្សោងនោះប្រកបដោយសូរសំឡេងដ៏ពីរោះផង។ ព្រានព័រ ក៏មានអារម្មណ៍សណ្ឋិតស្ងៀងនៅក្នុងរឿងនេះ ហើយក៏ពុំបានបាញ់សត្វទន្សោងនោះដែរ។ ជាមួយគ្នានោះ ក៏មានសត្វខ្លាមួយដែលប្រុងនឹងចាប់សត្វទន្សោង តែមិនបានចាប់ទៅវិញ ដោយបែរជាគោះជើងតាមចង្វាក់នៃការរេរាំរបស់សត្វទន្សោង។ ឃើញដូច្នោះហើយ ព្រានក៏ប្រញាប់ត្រឡប់ទៅទូលព្រះរាជាអំពីរឿងដ៏ចម្លែកនេះ។

របាំទន្សោង ត្រូវបានគេបង្កើតឡើងទៅតាមរឿងនិទានខាងលើនេះ។ម្យ៉ាងវិញទៀត គេជឿថា ព្រានឈ្មោះ «ព័រ» នោះក៏មានទំនាក់ទំនងជាមួយនឹងជនជាតិដើមភាគតិច «ព័រ» ដែលរស់នៅក្នុងតំបន់ជួរភ្នំក្រវាញនៃខេត្តកំពង់ឆ្នាំង កំពង់ស្ពឺ និងពោធិសាត់ដែរ។

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

# អត្ថបទ៖ របាំទន្សោង

នៅក្នុងការសម្ដែងរបាំទន្សោង គេរៀបដាក់នៅលើឆាក អ្នករាំពីរនាក់ស្លៀកពាក់ជាសត្វទន្សោងញីឈ្មោលមានទាំងពាក់ស្នែងទន្សោងផង ប្រកបដោយចលនានិងកាយវិការរេរាំប្រឡែងលេងនិងចែរចង់គ្នា។ អ្នករាំម្នាក់ស្លៀកពាក់ជាសត្វកន្ធង់ ផ្ទុំព្វយជានិមិត្តរូប រាំលេងនិងក្រឡឹងជុំវិញសត្វទន្សោង។ អ្នកវាយស្គរម្នាក់ អង្គុយនៅលើឆាកម្ខាងខាងក្រោយ ស្លៀកពាក់ជាសត្វខ្លា និងអ្នកច្រៀងម្នាក់ អង្គុយនៅលើឆាកខាងក្រោយម្ខាងទៀត ស្លៀកពាក់ជាព្រានព្រៃ ដោយមានស្ពាយស្នានៅខ្នង។ ពីក្នុងឆាកក្រោយវាំងនន មានអ្នកផ្ទុំឧបករណ៍ព្វយមែនទែនជាសូរដើម្បីកំដររបាំ។ ឯឈុតឆាកនិងសកម្មភាពនៃរបាំទន្សោង គឺមាននៅក្នុងអត្ថន័យខ្ទឹមសារដែលអ្នកច្រៀងបកស្រាយ។

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង






# ឯកសារពិគ្រោះ

Sam, Chan Moly, Nguon, Sam Ath, and Sam, Sam-Ang. (1998). *Khmer Folk Dance* (2nd ed.). Washington, DC: Cambodian Network Council.

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង